# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៤៤

## ស្ដីពី

## លក្ខន្តិកៈដោយឡែក

## នៃក្របខណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្ដីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## គ្រាស់បទ្ទាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

ព្រះរាជក្រឹត្យនេះ មានគោលបំណងបង្កើតក្របខណ្ឌដោយឡែករបស់អ្នករាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសរសេរកាត់ថា "អ.គ.ជ.ប" ដើម្បីកំណត់សិទ្ធិ តួនាទី ភារកិច្ច និងការទទួលខុសត្រូវ។

**មាត្រា២ ..**

ព្រះរាជក្រឹត្យនេះ មានគោលដៅកំណត់អំពីក្របខណ្ឌ ឋានន្តរសក្តិ ថ្នាក់ មុខតំណែង លក្ខខណ្ឌនៃការជ្រើសរើស ការធ្វើកម្មសិក្សា ការតាំងស៊ប់ ការបញ្ចេញពីក្របខណ្ឌ ការតែងតាំង ការដំឡើងឋានន្តរសក្តិ និងថ្នាក់ ការឈប់សម្រាក ការដាក់ទណ្ឌកម្មវិន័យ ការចោទប្រកាន់តាមផ្លូវតុលាការ និងការចូលនិវត្តន៍របស់ អ.គ.ជ.ប។

**មាត្រា៣ ..**

ព្រះរាជក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះ អ.គ.ជ.ប ដែលកំពុងបំពេញភារកិច្ចនៅក្នុងរចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និងលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ដែលសរសេរកាត់ថា "លធ.ខប"។

អ.គ.ជ.ប ត្រូវស្ថិតក្រោមការគ្រប់គ្រង និងការទទួលខុសត្រូវរបស់ គ.ជ.ប។

## ជំពូកទី២
## ក្របខណ្ឌ ឋានន្តរសក្តិ ថ្នាក់ និងមុខតំណែង

**មាត្រា៤ ..**

ក្របខណ្ឌរបស់ អ.គ.ជ.ប ត្រូវបានបែងចែកជា៣ (បី) ប្រភេទគឺៈ

១- **ប្រភេទ ក** - ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់

២- **ប្រភេទ ខ** - ក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម

៣- **ប្រភេទ គ** - ក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម។

**មាត្រា៥ ..**

ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ត្រូវបានបែងចែកជា៣ (បី) ឋានន្តរសក្តិៈ

- ឧត្តមមន្ត្រីមាន ៦ថ្នាក់
- វរមន្ត្រីមាន ៤ថ្នាក់
- អនុមន្ត្រីមាន ៤ថ្នាក់។

**មាត្រា៦ ..**

ក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យមត្រូវបានបែងចែកជា៣ (បី) ឋានន្តរសក្តិះ

- នាយក្រមការមាន ៦ថ្នាក់
- ក្រមការដើមខ្សែមាន ៤ថ្នាក់
- ក្រមការមាន ៤ថ្នាក់។

**មាត្រា៧ ..**

ក្របខណ្ឌមន្ត្រីបោះឆ្នោតបឋមមាន ១០ថ្នាក់។

**មាត្រា៨ ..**

ការរៀបចំសន្ទស្សន៍បៀវត្សនៃថ្នាក់នីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប អនុលោមតាមគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។ ការកំណត់ និងការកែប្រែតម្លៃឯកតាសន្ទស្សន៍បៀវត្ស ត្រូវអនុវត្តអនុលោមតម្លៃឯកតាសន្ទស្សន៍នៃបៀវត្ស របស់មន្ត្រីរាជការស៊ីវិល ដែលស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៩ ..**

អ.គ.ជ.ប ក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ មានមុខងារសម្រាប់កាន់មុខតំណែង ជាអ្នកដឹកនាំ គ្រប់គ្រង អធិការកិច្ច សវនកម្ម បណ្តុះបណ្តាល សិក្សាស្រាវជ្រាវ ផ្តល់យោបល់ គោលនយោបាយ ផែនការ និងមុខងារក្នុងរាល់មុខតំណែងទទួលខុសត្រូវ។

អ.គ.ជ.ប ក្នុងឋានន្តរសក្តិឧត្តមមន្ត្រី មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាអគ្គ លេខាធិការ អគ្គលេខាធិការរង និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ហើយដែលមាន នៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន។

អ.គ.ជ.ប ក្នុងឋានន្តរសក្តិវរមន្ត្រី មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាប្រធាន នាយកដ្ឋាន និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ហើយដែលមាននៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន។

អ.គ.ជ.ប ក្នុងឋានន្តរស័ក្តិអនុមន្ត្រី មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាអនុប្រធាននាយកដ្ឋាន ប្រធាន លធ.ខប និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ហើយដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន។

មុខតំណែង និងការពិព័ណ៌នាអំពីលក្ខខណ្ឌការងារនៃ អ.គ.ជ.ប ដែលកំពុងបំពេញភារកិច្ចនៅក្នុងរចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប នឹងត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

**មាត្រា១០ ៈ**

អ.គ.ជ.ប ក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម មានមុខងារក្នុងការរៀបចំការងារសម្រាប់អ្នកទទួលខុសត្រូវសម្រេច និងដាក់ឱ្យអនុវត្តការងារ បណ្តុះបណ្តាល ធានាប្រតិបត្តិការនៃការងារ និងជួយគាំទ្រដល់ការងារមន្ត្រីក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់។

អ.គ.ជ.ប ក្នុងឋានន្តរស័ក្តិនាយក្រមការ មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាអនុប្រធាន លធ.ខប ប្រធានការិយាល័យ និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ហើយដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន។

អ.គ.ជ.ប ក្នុងឋានន្តរស័ក្តិក្រមការដើមខ្សែ មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាអនុប្រធានការិយាល័យ និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ហើយដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន។

អ.គ.ជ.ប ក្នុងឋានន្តរស័ក្តិក្រមការ មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងមន្ត្រីជំនាញ និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ហើយដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន។

**មាត្រា១១ ៈ**

អ.គ.ជ.ប ក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាលេខាធិការ និងជាការីការងាររដ្ឋបាល។

**មាត្រា១២ ៈ**

អ.គ.ជ.ប ដែលមានឋានន្តរស័ក្តិក្នុងមុខតំណែងណាមួយ អាចត្រូវផ្លាស់ប្តូរទៅកាន់មុខតំណែងផ្សេងទៀតបាន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៣ ..**

ប្រាក់បំណាច់មុខងារ ប្រាក់បំណាច់បោះឆ្នោត ប្រាក់ឧបត្ថម្ភពេលប្រតិបត្តិការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត ប្រាក់វិភាជន៍គ្រួសារ ប្រាក់បំប៉នផ្គត់ផ្គង់ជីវភាពផ្សេងៗនៃ អ.គ.ជ.ប ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។ របបសន្តិសុខសង្គមដែលរួមមាន សោធននិវត្តន៍ សោធនបាត់បង់សម្បទាវិជ្ជាជីវៈ និងតាវកាលិកផ្សេងៗទៀត ត្រូវអនុវត្តអនុលោមបទប្បញ្ញត្តិ និងនីតិវិធីដែលមានជាធរមានសម្រាប់មន្ត្រីរាជការស៊ីវិលដែលស្ថិតក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៤ ..**

សញ្ញាសក្តិ និងឯកសណ្ឋានសម្រាប់ អ.គ.ជ.ប ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសេចក្តីស្នើរបស់ប្រធាន គ.ជ.ប។

## ជំពូកទី៣
## ការជ្រើសរើសឱ្យចូលធ្វើការ

**មាត្រា១៥ ..**

រាល់ការជ្រើសរើស អ.គ.ជ.ប ក្នុងក្របខណ្ឌណាមួយ ត្រូវធ្វើឡើងតាមការប្រឡងប្រជែង។ ការជ្រើសរើសត្រូវបានលើកទឹកចិត្តចំពោះបេក្ខជនជាស្ត្រី ជនជាតិដើមភាគតិច និងជនដែលមានពិការភាព។

**មាត្រា១៦ ..**

បេក្ខជនទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- មានសញ្ជាតិខ្មែរ

២- មានអាយុពី១៨ (ដប់ប្រាំបី) ឆ្នាំឡើង រហូតដល់អាយុ៣៥ (សាមសិបប្រាំ) ឆ្នាំគិតមកដល់ថ្ងៃប្រឡង

៣- មានសំបុត្រថ្កោលទោស

៤- មានកិរិយាមារយាទល្អ

៥- មានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងសេចក្តីត្រូវការ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា១៧ ៖**

កាលបរិច្ឆេទនៃការប្រឡងជ្រើសរើសត្រូវផ្សព្វផ្សាយជាសាធារណៈឱ្យបាន៦០ (ហុកសិប) ថ្ងៃ មុនពេលប្រឡង។ ក្នុងករណីប្រញាប់ ការផ្សព្វផ្សាយត្រូវធ្វើយ៉ាងតិច៣០ (សាមសិប) ថ្ងៃមុន។

**មាត្រា១៨ ៖**

ការប្រឡងចូលក្របខណ្ឌណាមួយ គ.ជ.ប ត្រូវតែងតាំងគណៈកម្មការជ្រើសរើសមួយ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- តំណាង គ.ជ.ប | ប្រធាន |
| ២- អគ្គលេខាធិការ ឬតំណាង | អនុប្រធាន |
| ៣- ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៤- ប្រធាននាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៥- អ.គ.ជ.ប ២ (ពីរ) នាក់ក្នុងក្របខណ្ឌជាមួយ | សមាជិក។ |

**មាត្រា១៩ ៖**

អាចប្រឡងចូលក្របខណ្ឌ៖

- មន្ត្រីបោះឆ្នោតជាន់ខ្ពស់ បេក្ខជនដែលមានសញ្ញាបត្រកម្រិតអប្បបរមាបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល។
- មន្ត្រីបោះឆ្នោតមធ្យម បេក្ខជនដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបូកវគ្គបណ្ដុះបណ្ដាលរយៈពេល២ (ពីរ) ឆ្នាំ ដោយមានវិញ្ញាបនបត្រ ឬសញ្ញាបត្រ ឬ/និងមន្ត្រីស្ថិតក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម ដែលកំពុងបំពេញការងារនៅអគ្គលេខាធិការដ្ឋាន គ.ជ.ប ឬ លធ.ខប។
- មន្ត្រីបោះឆ្នោតបឋម បេក្ខជនដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

**មាត្រា២០ ៖**

ផែនការតម្រូវការចំនួន អ.គ.ជ.ប ប្រចាំឆ្នាំ ជាសមត្ថកិច្ចរបស់ គ.ជ.ប តាមសេចក្ដីស្នើរបស់អគ្គលេខាធិការ។

ក្នុងករណីចាំបាច់ គ.ជ.ប អាចសម្រេចតែងតាំង អ.គ.ជ.ប តាមតម្រូវការជាក់ស្ដែង។

## ជំពូកទី៤
## ការធ្វើកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខណ្ឌ ការបញ្ចេញពីក្របខណ្ឌ

**មាត្រា២១ ..**

រយៈពេលកម្មសិក្សាត្រូវកម្រិត១២ (ដប់ពីរ) ខែ។ រយៈពេលកម្មសិក្សាត្រូវគិតតាំងពីថ្ងៃតែងតាំងកម្មសិក្សាការីនោះ។

កម្មសិក្សានេះមិនត្រូវយកជាការបានទេ បើកាលណាសាមីជនខកខានពុំបានមកធ្វើកម្មសិក្សាសរុប៣០ (សាមសិប) ថ្ងៃ។ ក្នុងករណីនេះ សាមីជនត្រូវបន្តធ្វើកម្មសិក្សានៅលើកទី២ ទៀត។ ការបន្តធ្វើកម្មសិក្សាលើកទី២ ត្រូវមានរយៈពេលស្មើនឹងរយៈពេលលើកទី១ ដែរ។

មិនបាច់ធ្វើកម្មសិក្សា ចំពោះ អ.គ.ជ.ប ទាំងឡាយដែលបានប្រឡងជាប់ទៅកាន់ក្របខណ្ឌខ្ពស់ជាងនៃជំនាញដែលខ្លួនធ្លាប់ជា អ.គ.ជ.ប ចាស់ ដោយបានតាំងស៊ប់ក្នុងក្របខណ្ឌម្តងរួចមកហើយ។

**មាត្រា២២ ..**

ការតាំងស៊ប់ត្រូវសម្រេចក្នុងរយៈពេលមិនលើសពី៣ (បី) ខែ ក្រោយថ្ងៃផុតកំណត់រយៈពេលកម្មសិក្សា។

ការតាំងស៊ប់ចាប់ផ្តើមមានប្រសិទ្ធភាពខាងផ្នែកបៀវត្ស ក៏ដូចជាអតីតភាពការងារសម្រាប់ឡើងថ្នាក់។ ប៉ុន្តែអតីតភាពការងារសម្រាប់ចូលនិវត្តន៍ត្រូវបានគិតបញ្ចូលតាំងពីពេលចាប់ផ្តើមធ្វើកម្មសិក្សា។ ការតាំងស៊ប់ត្រូវសម្រេចដោយ គ.ជ.ប បន្ទាប់ពីមានការផ្តល់យោបល់ពីគណៈកម្មការវាយតម្លៃមួយដែលមានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១- តំណាង គ.ជ.ប | ប្រធាន |
| ២- អគ្គលេខាធិការ ឬតំណាង | អនុប្រធាន |
| ៣- ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៤- ប្រធាននាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៥- អ.គ.ជ.ប ២ (ពីរ) នាក់ ដែលមានក្របខណ្ឌដូចគ្នា | សមាជិក។ |

**មាត្រា២៣ ..**

កម្មសិក្សាការី ណាដែលមិនមានសម្បទាវិជ្ជាជីវៈគ្រប់គ្រាន់ ធ្វើការខ្ជីខ្ជា មិនគោរពវិន័យ ឬក៏គ្មានកម្លាំងពលំនឹងកាន់មុខតំណែងបាន អាចត្រូវបានបញ្ឈប់មិនឱ្យធ្វើការ ឬផ្ទេរទៅកាន់ក្របខណ្ឌដើមវិញ ពេលណាក៏បាន ក្នុងរយៈពេលបំពេញកម្មសិក្សា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា២៤ ៈ**

អ.គ.ជ.ប ណា ដែលធ្វើការតទៅទៀតមិនបាន ដោយហេតុមកពីបាត់បង់សម្បទាវិជ្ជាជីវៈ ហើយដែលមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលសោធននិវត្តន៍ ត្រូវបានចាត់ទុកថា បាត់បង់សមត្ថភាពការងារ ហើយត្រូវបញ្ឈប់មិនឱ្យធ្វើការតទៅទៀត។

ក្នុងករណីនេះ សាមីជនត្រូវបានទទួលប្រាក់ធានារ៉ាប់រងសង្គមម្តងគត់ និងប្រាក់ដែលបានកាត់ទុកសម្រាប់សោធននិវត្តន៍។ បើ អ.គ.ជ.ប នោះមានអតីតភាពការងារលើសពី២០ (ម្ភៃ) ឆ្នាំ សាមីជនត្រូវបានតម្រូវឱ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ ដោយទទួលប្រាក់សោធននិវត្តន៍សមាមាត្រ។

ការកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវសម្រេចដោយ គ.ជ.ប បន្ទាប់ពីមានការផ្តល់យោបល់ពីគណៈកម្មការដែលមានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| ១- តំណាង គ.ជ.ប | ប្រធាន |
| ២- អគ្គលេខាធិការ ឬតំណាង | អនុប្រធាន |
| ៣- ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៤- ប្រធាននាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៥- គ្រូពេទ្យដែលបានទទួលសច្ចាប្រណិធាន និង ដែលត្រូវបានចាត់ឡើងដោយក្រសួងសុខាភិបាល | សមាជិក |
| ៦- អ.គ.ជ.ប ដែលមានក្របខណ្ឌជាមួយគ្នា១ (មួយ) នាក់ ដែលមានឋានន្តរសក្តិយ៉ាងហោចណាស់ស្មើនឹងសាមីជន | សមាជិក។ |

## ជំពូកទី៥
## ការតែងតាំង ការដំឡើងឋានន្តរសក្តិ ថ្នាក់ និងគ្រឿងឥស្សរិយយស

**មាត្រា២៥ ៈ**

ការតែងតាំងសម្រាប់ អ.គ.ជ.ប ឱ្យកាន់មុខតំណែងណាមួយ ត្រូវតែផ្អែកតាមអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានដែលមានកន្លែងទំនេរ។

**មាត្រា២៦ ៈ**

នៅក្របខណ្ឌនីមួយៗ អ.គ.ជ.ប ក្នុងឋានន្តរសក្តិ ឬថ្នាក់ណាមួយ មិនអាចចាត់ឱ្យទៅធ្វើការក្រោមបង្គាប់ អ.គ.ជ.ប ម្នាក់ទៀត ដែលមានឋានន្តរសក្តិ ឬថ្នាក់ទាបជាងខ្លួនទេ លើកលែងតែក្នុងករណីចាំបាច់ ហើយសាមីខ្លួនដែលមានឋានន្តរសក្តិ ឬថ្នាក់ធំជាងនោះយល់ព្រម។

**មាត្រា២៧ ..**

ការដំឡើងថ្នាក់ជូន អ.គ.ជ.ប ត្រូវធ្វើតាមវេនជ្រើសរើសក៏បាន ឬតាមវេនជ្រើសរើស និងអតីតភាពជាមួយគ្នាក៏បាន។

**មាត្រា២៨ ..**

ការដំឡើងថ្នាក់ជូន អ.គ.ជ.ប ត្រូវកំណត់តាមលក្ខខណ្ឌដូចខាងក្រោម៖

១- មានអតីតភាពការងារ២ (ពីរ) ឆ្នាំយ៉ាងតិច

២- មានលទ្ធផលល្អក្នុងការបំពេញការងារ

៣- គោរពវិន័យបានល្អ

៤- មានសាមគ្គីភាពផ្ទៃក្នុងល្អ។

ក្នុងករណីមាន អ.គ.ជ.ប ណាបំពេញការងារបានល្អវិសេស អ.គ.ជ.ប នោះត្រូវបានដំឡើងថ្នាក់ជាស្វ័យប្រវត្តិ ដោយមិនគិតពីលក្ខខណ្ឌអតីតភាពការងារឡើយ។

ការដំឡើងថ្នាក់នៅក្នុងឋានន្តរសក្តិឧត្តមមន្ត្រីនៃក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រធាន គ.ជ.ប ផ្អែកតាមការសម្រេចរបស់ គ.ជ.ប។ ការដំឡើងថ្នាក់ក្នុងឋានន្តរសក្តិវរមន្ត្រី និងឋានន្តរសក្តិអនុមន្ត្រីនៃក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ និងក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម ក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

**មាត្រា២៩ ..**

អ.គ.ជ.ប ក្នុងក្របខណ្ឌណាមួយអាចឡើងថ្នាក់បាន ម្តងមួយថ្នាក់។

នៅពេល អ.គ.ជ.ប ត្រូវប្តូរក្របខណ្ឌខ្ពស់ទៀតដោយសារបានប្រឡងជាប់ សន្ទស្សន៍បៀវត្សត្រូវគិតតាមឋានន្តរសក្តិដំបូងនៃក្របខណ្ឌថ្មី។ ប៉ុន្តែបើបៀវត្សនៅទាបជាងបៀវត្សចាស់ ត្រូវរៀបត្រឹមថ្នាក់ដែលមានកម្រិតស្មើ ឬខ្ពស់បន្ទាប់ពីសន្ទស្សន៍បៀវត្សក្របខណ្ឌចាស់នៃ អ.គ.ជ.ប នោះ។ អតីតភាពការងារដើម្បីដំឡើងថ្នាក់ត្រូវគិតពីថ្ងៃដែលបានទទួលបៀវត្សថ្នាក់ចុងក្រោយ។

ការដំឡើងថ្នាក់ត្រូវសម្រេចដោយ គ.ជ.ប និងស្របតាមកម្រិតមុខចំណាយថវិកា។

**មាត្រា៣០ ..**

អ.គ.ជ.ប ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ ដែលមានសញ្ញាបត្រខ្ពស់ជាងបរិញ្ញាបត្រ ត្រូវបានដំឡើងថ្នាក់ ១ថ្នាក់ជាស្វ័យប្រវត្តិ។

អ.គ.ជ.ប ក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម ដែលមានបរិញ្ញាបត្រ ឬសញ្ញាបត្រមានតម្លៃសមមូល ត្រូវបានដំឡើងថ្នាក់ ១ថ្នាក់ជាស្វ័យប្រវត្តិ។

អ.គ.ជ.ប ក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម ដែលមានសញ្ញាបត្រខ្ពស់ជាងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ត្រូវបានដំឡើងថ្នាក់ ១ថ្នាក់ជាស្វ័យប្រវត្តិ។

**មាត្រា៣១ ..**

ជារៀងរាល់ឆ្នាំ នៅខែមករា នាយកដ្ឋានរដ្ឋបាលត្រូវចុះបញ្ជីនៃ អ.គ.ជ.ប ដែលមានសិទ្ធិត្រូវដំឡើងថ្នាក់ ដោយបញ្ជូនព្រឹត្តិបត្រពិន្ទុទៅការិយាល័យ និងនាយកដ្ឋានសាមីដើម្បីដាក់ពិន្ទុ និងចុះមូលវិចារណ៍ដល់សាមីជនម្នាក់ៗ។ បន្ទាប់ពីដាក់ពិន្ទុ និងចុះមូលវិចារណ៍រួចហើយ ការិយាល័យ និងនាយកដ្ឋានសាមី ត្រូវបញ្ជូនព្រឹត្តិបត្រពិន្ទុទាំងនោះទៅនាយកដ្ឋានរដ្ឋបាលវិញ ដើម្បីធ្វើបញ្ជីចំណាត់ថ្នាក់រួម សម្រាប់រាយការណ៍ជូនគណៈកម្មការដំឡើងថ្នាក់។

**មាត្រា៣២ ..**

អគ្គលេខាធិការបញ្ឈប់បញ្ជី អ.គ.ជ.ប ដែលត្រូវបានស្នើពិនិត្យដំឡើងថ្នាក់ រួចបញ្ជូនទៅគណៈកម្មការដំឡើងថ្នាក់ ដើម្បីធ្វើការប្រជុំ។

សមាសភាពគណៈកម្មការដំឡើងថ្នាក់មានដូចតទៅ៖

| | |
|---|---|
| ១- តំណាង គ.ជ.ប | ប្រធាន |
| ២- អគ្គលេខាធិការ ឬតំណាង | អនុប្រធាន |
| ៣- ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៤- ប្រធាននាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៥- អ.គ.ជ.ប ដែលមានក្របខណ្ឌជាមួយ ២ (ពីរ) នាក់ | សមាជិក។ |

**មាត្រា៣៣ ..**

ការដំឡើងថ្នាក់ត្រូវធ្វើនៅខែមេសានៃឆ្នាំនីមួយៗ។

អ.គ.ជ.ប ដែលមានឈ្មោះក្នុងបញ្ជី ប៉ុន្តែមិនបានឡើងថ្នាក់ មានអាទិភាពក្នុងការដំឡើងថ្នាក់នាឆ្នាំបន្ទាប់។ អ.គ.ជ.ប ម្នាក់ៗមានសិទ្ធិសុំមើលដោយផ្ទាល់តំបាំងនូវសំណុំរឿងផ្ទាល់ខ្លួន។

**មាត្រា៣៤ ..**

សិទ្ធិឡើងថ្នាក់ត្រូវផ្អាកទុកសិនចំពោះ អ.គ.ជ.ប ណាដែលទទួលទណ្ឌកម្មថ្នាក់ទី២ ផ្នែកវិន័យ ឬទទួលការចោទប្រកាន់តាមផ្លូវតុលាការ និងអ្នកដែលត្រូវបានដាក់ឱ្យនៅទំនេរគ្មានរបៀវត្សរ៍ចាប់ពីរយៈពេល៦ (ប្រាំមួយ) ខែឡើងទៅ។

**មាត្រា៣៥ ..**

អ.គ.ជ.ប ដែលមានស្នាដៃល្អក្នុងការបំពេញការងារ អាចទទួលគ្រឿងឥស្សរិយយស។

លក្ខខណ្ឌ និងបែបបទនៃការផ្តល់គ្រឿងឥស្សរិយយស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

ឋានន្តរសក្តិកិត្តិយសអាចផ្តល់ដោយ គ.ជ.ប ជូន អ.គ.ជ.ប ចូលនិវត្តន៍ ឬលាលែង ឬដាក់ឱ្យឈប់ធ្វើការដោយបាត់បង់សមត្ថភាពការងារ ឬទទួលមរណភាព បន្ទាប់ពីបានបំពេញការងារអស់រយៈពេលយូរ និងមានស្នាដៃល្អ។

## ជំពូកទី៦
## ការឈប់សម្រាក

**មាត្រា៣៦ ..**

អ.គ.ជ.ប មានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំចំនួន១៥ (ដប់ប្រាំ) ថ្ងៃ បន្ថែមពីលើថ្ងៃឈប់សម្រាកដែលកំណត់ដោយរាជរដ្ឋាភិបាល។

អ.គ.ជ.ប នារីមានសិទ្ធិឈប់សម្រាកលំហែមាតុភាពចំនួន៩០ (កៅ សិប) ថ្ងៃ។

អ.គ.ជ.ប ដែលមានធុរៈអាចត្រូវបានអនុញ្ញាតច្បាប់ឱ្យឈប់សម្រាកពីការងារ។

**មាត្រា៣៧ ..**

អ.គ.ជ.ប ដែលមានអតីតភាពការងារយ៉ាងតិច៣ (បី) ឆ្នាំ មានសិទ្ធិស្នើសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដែលមានរយៈពេលម្តងៗ មិនតិចជាង៦ (ប្រាំមួយ) ខែ និងមិនលើសពី២ (ពីរ) ឆ្នាំ ហើយអាចបន្តជាថ្មី សរុបទាំងអស់មិនឱ្យហួសពី៤ (បួន) ឆ្នាំ។

បែបបទលក្ខខណ្ឌ និងរយៈពេលនៃការឈប់នេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

## ជំពូកទី៧
## វិន័យ

**មាត្រា៣៨ ..**

អ.គ.ជ.ប គ្រប់រូបត្រូវប្រតិបត្តិតាមច្បាប់ បទបញ្ជាផ្ទៃក្នុង គ.ជ.ប ក្រមសីលធម៌ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ហើយត្រូវគោរពគោលការណ៍អព្យាក្រឹតឥតលម្អៀង មិនប្រកាន់គណបក្សនយោបាយក្នុងពេលបំពេញការងារ។ អ.គ.ជ.ប ត្រូវមានគណនេយ្យភាពតាមឋានានុក្រមចំពោះ គ.ជ.ប អំពីកិច្ចការ និងអំពើរបស់ខ្លួនដែលបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងកិត្តិយសនៃ អ.គ.ជ.ប ទោះបីកិច្ចការនោះប្រព្រឹត្តនៅមជ្ឈដ្ឋានខាងក្រៅក៏ដោយ។

**មាត្រា៣៩ ..**

អ.គ.ជ.ប រាល់រូបមិនអាចអវត្តមានដោយគ្មានការអនុញ្ញាត ឬដោយគ្មានមូលហេតុត្រឹមត្រូវបានឡើយ។

អវត្តមានដោយគ្មានការអនុញ្ញាត ឬដោយគ្មានមូលហេតុត្រឹមត្រូវអាចឱ្យ អ.គ.ជ.ប នោះទទួលទណ្ឌកម្មខាងវិន័យ។

**មាត្រា៤០ ..**

អ.គ.ជ.ប មិនត្រូវ៖

- យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួន
- ប្រើឥទ្ធិពល និងអំណាចក្នុងមុខងាររបស់ខ្លួន ដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬសំឡុតគំរាមកំហែងបំពានសិទ្ធិរបស់ពលរដ្ឋ
- គ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬដោយប្រយោល
- បោះពុម្ពផ្សាយ ឬផ្សព្វផ្សាយព័ត៌មានដែលទាក់ទងនឹងការងាររបស់ គ.ជ.ប ដោយគ្មានការអនុញ្ញាតជាមុនពី គ.ជ.ប។

អំពើបំពាននឹងបទប្បញ្ញត្តិនៃមាត្រានេះ អាចបណ្ដាលឱ្យទទួលទណ្ឌកម្មផ្នែកវិន័យណាមួយដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទអាជ្ញាដែលអាចកើតមានឡើងទៀតផង។

**មាត្រា៤១ ..**

ទណ្ឌកម្មខាងវិន័យមានដូចតទៅ៖

### ១- ទណ្ឌកម្មថ្នាក់ទី ១

ក- ស្ដីបន្ទោស

ខ- ស្ដីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ- ផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ។

### ២- ទណ្ឌកម្មថ្នាក់ទី ២

ក- លុបឈ្មោះចេញពីបញ្ជីដំឡើងថ្នាក់ បើសិនជាមានចុះឈ្មោះហើយ ឬមិនដំឡើងថ្នាក់ក្នុងថេរវេលាមួយមិនលើសពី២ (ពីរ) ឆ្នាំ

ខ- ដាក់ឱ្យនៅទំនេរគ្មានបៀវត្សមិនលើសពី១ (មួយ) ឆ្នាំ

គ- បន្ថយឋានន្តរសក្តិ ឬថ្នាក់មួយថ្នាក់ ឬច្រើនថ្នាក់

ឃ- ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ពីការងារដោយបង្ខំ

ង- បណ្តេញចេញពីមុខតំណែងរាជការ។

លក្ខខណ្ឌស្តីពីទណ្ឌកម្មវិន័យចំពោះ អ.គ.ជ.ប ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

## ជំពូកទី៨
## ការចោទប្រកាន់តាមផ្លូវតុលាការ

**មាត្រា៤២ ..**

អ.គ.ជ.ប ដែលត្រូវបានតុលាការកំពុងចោទប្រកាន់ ហើយដែលត្រូវបានបញ្ជូនខ្លួនឱ្យតុលាការជំនុំជម្រះអាចត្រូវបានផ្អាកការងារសិនក្នុងករណីចាំបាច់។

ក្នុងករណីដែល អ.គ.ជ.ប ណាម្នាក់ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់នោះទៅ គ.ជ.ប ក្នុងរយៈពេល៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ។

ក្នុងករណីដែលបទល្មើសនោះ កើតមានក្នុងក្របខណ្ឌនៃការបម្រើការងារបោះឆ្នោត គ.ជ.ប ត្រូវការពារ អ.គ.ជ.ប នោះតាមផ្លូវច្បាប់។

**មាត្រា៤៣ ..**

ក្នុងករណីដែល អ.គ.ជ.ប ត្រូវបានផ្អាកពីការងារបណ្តាលមកពីជាប់ចោទតាមផ្លូវតុលាការជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ហើយត្រូវបានតុលាការសម្រេចថា គ្មានទោស អ.គ.ជ.ប នោះត្រូវបានអនុញ្ញាតឱ្យចូលធ្វើការវិញភ្លាម ដោយគិតពីអតីតភាព ឋានន្តរសក្តិ សោធននិវត្តន៍ និងទទួលបៀវត្សប្រតិសកម្មផង។

**មាត្រា៤៤ ..**

អ.គ.ជ.ប ដែលតុលាការបានកាត់ទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋត្រូវលុបឈ្មោះចេញពី អ.គ.ជ.ប ចាប់ពីថ្ងៃដែលសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ។

## ជំពូកទី៩
## ការចូលនិវត្តន៍

**មាត្រា៤៥ ..**

អ.គ.ជ.ប ត្រូវបានដាក់ឱ្យចូលនិវត្តន៍នៅអាយុ៦០ (ហុកសិប) ឆ្នាំ។

**មាត្រា៤៦ ..**

អ.គ.ជ.ប ដែលដល់អាយុចូលនិវត្តន៍ ហើយមានអតីតភាពការងារក្នុងចន្លោះពី២០ (ម្ភៃ) ឆ្នាំដល់ក្រោម៣០ (សាមសិប) ឆ្នាំ ត្រូវបានទទួលប្រាក់សោធននិវត្តន៍សមាមាត្រ។

**មាត្រា៤៧ ..**

អ.គ.ជ.ប ដែលដល់អាយុចូលនិវត្តន៍ ហើយមានអតីតភាពការងារ៣០ (សាមសិប) ឆ្នាំយ៉ាងតិចត្រូវបានទទួលប្រាក់សោធននិវត្តន៍អតីតភាព។ ប៉ុន្តែ អ.គ.ជ.ប ដែលបម្រើការងារអស់រយៈពេល៣០ (សាមសិប) ឆ្នាំ អាចសុំចូលនិវត្តន៍មុនដល់អាយុត្រូវចូលនិវត្តន៍បាន ដោយត្រូវបានទទួលប្រាក់សោធននិវត្តន៍អតីតភាព។

**មាត្រា៤៨ ..**

អ.គ.ជ.ប ដែលបានបម្រើការងារក្រោម២០ (ម្ភៃ) ឆ្នាំ ហើយដល់អាយុចូលនិវត្តន៍ ត្រូវទទួលប្រាក់សោធននិវត្តន៍ដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗតែមួយលើក។

**មាត្រា៤៩ ..**

ចំពោះ អ.គ.ជ.ប ដែលមានអតីតភាពការងារគ្រប់៣០ (សាមសិប) ឆ្នាំហើយ ហើយមិនទាន់ដល់អាយុចូលនិវត្តន៍ទេនោះ មិនត្រូវបានកាត់ទុកប្រាក់សោធននិវត្តន៍ឡើយ។

**មាត្រា៥០ ..**

អតីតភាពការងារសម្រាប់ចូលនិវត្តន៍របស់ អ.គ.ជ.ប ត្រូវគិតតាំងពីថ្ងៃដែលសាមីជនចូលបម្រើការងាររដ្ឋ ទោះក្នុងសម័យណាក៏ដោយ។

## ជំពូកទី១០
## បទប្បញ្ញត្តិដោយឡែក

**មាត្រា៥១ ..**

ប្រធាន គ.ជ.ប អនុប្រធាន គ.ជ.ប និងសមាជិក គ.ជ.ប អាចចាត់តាំងមន្ត្រីមួយចំនួនឱ្យបម្រើការងារផ្ទាល់ តាមអង្គការលេខរបស់ គ.ជ.ប ទោះបីសាមីជននោះពុំមែនជាមន្ត្រីក្របខណ្ឌក៏ដោយ។ ក្នុងករណីនេះ សាមីជនដែលទទួលការតែងតាំងមានសិទ្ធិទទួលប្រាក់បំណាច់ផ្ទៃធម្មសិ តែគ្មានសិទ្ធិទទួលប្រាក់សោធននិវត្តន៍ទេ ហើយបញ្ចប់មុខតំណែងរបស់ខ្លួនតាមអាណត្តិរបស់ គ.ជ.ប។

**មាត្រា៥២ ..**

ផ្អែកលើការចាំបាច់ក្នុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងពេលបោះឆ្នោត គ.ជ.ប អាចជ្រើសរើស និងតែងតាំងមន្ត្រីចាំបាច់មួយចំនួនឱ្យបម្រើការងារ ទោះបីសាមីជននោះពុំមែនជាមន្ត្រីក្របខណ្ឌក៏ដោយ។ ក្នុងករណីនេះ សាមីជនមានសិទ្ធិទទួលប្រាក់បំណាច់ជាធម្មតាទៅតាមកិច្ចសន្យា តែមិនមានសិទ្ធិទទួលប្រាក់សោធននិវត្តន៍ទេ ហើយបញ្ចប់មុខតំណែងរបស់ខ្លួនតាមការកំណត់របស់ គ.ជ.ប។

## ជំពូកទី១១
## អន្តរប្បញ្ញត្តិ

**មាត្រា៥៣ ..**

អគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិកនៃ គ.ជ.ប ត្រូវបន្តការងារជាអគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិកនៃ គ.ជ.ប ដែលបានរៀបចំឡើងតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប រហូតដល់មានការតែងតាំងថ្មី ស្របតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប។

ការផ្លាស់ប្តូរ និងតែងតាំងអគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិកនៃ គ.ជ.ប ត្រូវធ្វើឡើងដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប។

មន្ត្រី បុគ្គលិកដែលកំពុងបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប និង លធ.ខប ត្រូវបានធ្វើសមាហរណកម្មទៅក្នុងក្របខណ្ឌនៃលក្ខន្តិកៈដោយឡែក ដូចមានចែងក្នុងកថាខណ្ឌទី៤ នៃមាត្រា៥៥ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប។

គោលការណ៍នៃការធ្វើសមាហរណកម្មមន្ត្រី បុគ្គលិកដែលកំពុងបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប និង លធ.ខប បច្ចុប្បន្ន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

**មាត្រា៥៤ ..**

ចាប់ពីព្រះរាជក្រឹត្យនេះ ចូលជាធរមាន អ.គ.ជ.ប ដែលមានអាយុលើសពីការកំណត់ អាចអនុញ្ញាតបន្តឱ្យធ្វើការបានតាមការស្នើសុំរបស់សាមីខ្លួន១ (មួយ) ឆ្នាំម្តងៗ និងតាមការសម្រេចពី គ.ជ.ប ដោយសំឡេងភាគច្រើនដាច់ខាត តាមតម្រូវការជាក់ស្តែង ផ្អែកលើយោបល់របស់អគ្គលេខាធិការ និងប្រធានអង្គភាពសាមី។

ការស្នើសុំពន្យារនេះ មិនឱ្យលើសពី៤ (បួន) ដងទេ។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា៥៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៦ .-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៥

នរស.១៥០៦.៦៥៤

**បានប្រូវថាប់ព្រះរាជលញ្ចករហើយ**

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតី ហ៊ុន សែន នាយករដ្ឋមន្ត្រី
**ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ស៊ិក ប៊ុនហុក**